**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ២៣៥/២៤ ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាស្តារនីតិសម្បទា សេវាឬការព្យាបាលនិងការថែទាំវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូលនិងការផ្តល់សេវាបង្ការសុខភាព និងការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាស្តារនីតិសម្បទា សេវាឬការព្យាបាលនិងការថែទាំវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូលនិងការផ្តល់សេវាបង្ការសុខភាព និងការកំណត់បញ្ជីជំងឺពុំរ៉ៃក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច សំដៅជានាប្រសិទ្ធភាពនៃការអនុវត្តរបបសន្តិសុខសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

| | |
|---|---|
| **១- ការព្យាបាលដោយកាំរស្មីឡាស៊ែរ** | សំដៅដល់ការព្យាបាលបែបវេជ្ជសាស្ត្រ ដែលប្រើពន្លឺដ៏ខ្លាំងមួយដើម្បីកាត់ ដុត ឬបំផ្លាញជាលិកា។ |
| **២- ការព្យាបាលដោយខ្លួនឯង** | សំដៅដល់ការព្យាបាលដោយគ្មានវេជ្ជបញ្ជាពីមូលដ្ឋានសុខាភិបាលជាដៃគូបេឡាជាតិសន្តិសុខសង្គម(**ប.ស.ស.**) លើកលែងតែករណីសង្គ្រោះបន្ទាន់។ |
| **៣- ការហ្វឹកហាត់កាយសម្បទា** | សំដៅដល់ការហ្វឹកហាត់ ឬការព្យាបាលពិការភាពដោយអ្នកជំនាញខាងហ្វឹកហាត់កាយសម្បទា ដើម្បីអភិវឌ្ឍ ឬធ្វើឱ្យប្រសើរឡើងវិញ ឬថែរក្សាបាននូវសមត្ថភាព និងមុខងារសម្រាប់បំពេញតម្រូវការចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ។ |
| **៤- ប័ណ្ណសមាជិក ប.ស.ស. មានសុពលភាព** | សំដៅដល់ប័ណ្ណសមាជិក **ប.ស.ស.** គ្រប់ទម្រង់ ដែលគោរពតាមលក្ខខណ្ឌបង់ភាគទាន និងអនុញ្ញាតឱ្យសមាជិក **ប.ស.ស.** មានសិទ្ធិប្រើប្រាស់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ នៅតាមបណ្តាមូលដ្ឋានសុខាភិបាលដៃគូ **ប.ស.ស.** តាមរយៈការផ្ទៀងផ្ទាត់ជាមួយប្រព័ន្ធ NSSF Agent ឬកម្មវិធីសមាជិក **ប.ស.ស.** ក្នុងទូរស័ព្ទដៃ (NSSF Member App) ឬមធ្យោបាយផ្លូវការនានារបស់ **ប.ស.ស.** ដែលបង្ហាញថា "មានសុពលភាព"។ |

៥- មូលដ្ឋានសុខាភិបាល — សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

៦- រណប — សំដៅដល់ឧបករណ៍ខាងក្រៅប្រើសម្រាប់អបផ្នែករាងកាយដែលទន់ខ្សោយសាច់ដុំ ឬខូចទ្រង់ទ្រាយដើម្បីជំនួយដល់ការធ្វើចលនា ឬការធ្វើការងារផ្សេង។

៧- សេវាជំនួយវេជ្ជសាស្ត្រ — សំដៅដល់ការព្យាបាលដោយស្អំ និងដោយចលនា។

៨- សេវាបង្ការសុខភាព — សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្ត-សញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងការអន្តរាគមន៍ចាំបាច់ដទៃទៀត ដើម្បីការពារកុំឱ្យមានបញ្ហាសុខភាព មានជាអាទិ៍ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព និងកម្មវិធីចាក់ថ្នាំបង្ការ។

៩-សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ — សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។

១០- សេវាវេជ្ជសាស្ត្រ — សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។

១១- សេវាសង្គ្រោះបន្ទាន់ — សំដៅដល់អន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក និងត្រូវធ្វើបន្ទាន់ក្នុងគោលបំណងសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវយវៈ ឬសរីរាង្គណាមួយរបស់ជនរងគ្រោះ ឬអ្នកជំងឺ។

១២-សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ — សំដៅដល់ការផ្តល់ ការជួសជុល ឬការផ្តល់ជាថ្មីនូវអវយវៈសិប្បនិម្មិត រណប ឬឧបករណ៍ជំនួយ ការហ្វឹកហាត់កាយសម្បទាឡើងវិញ ការព្យាបាលដោយចលនា និងការផ្តល់សេវាស្តារ-នីតិសម្បទាផ្នែកវេជ្ជសាស្ត្រដទៃទៀត។

១៣- សេវាអមវេជ្ជសាស្ត្រ — សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។

១៤- អវយវៈសិប្បនិម្មិត — សំដៅដល់ឧបករណ៍សិប្បនិម្មិតខាងក្រៅ ដែលប្រើសម្រាប់ជំនួសផ្នែកទាំងស្រុង ឬផ្នែកណាមួយ នៃអវយវៈដែលបាត់បង់។

១៥- អ្នកតំណាង — សំដៅដល់សហព័ទ្ធ កូន សាច់ញាតិ ឬអ្នកតំណាងស្របច្បាប់របស់សមាជិក **ប.ស.ស.**។

១៦- ឧបករណ៍ជំនួយ — សំដៅដល់ឧបករណ៍ ឬវត្ថុប្រើសម្រាប់ជំនួយដល់ការចល័ត ឬការបម្លាស់ទីរបស់ជនមានពិការភាព។

១៧- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត — សំដៅដល់ឧបករណ៍វ៉ែនតា ឬឡង់ទីជំនួយភ្នែក (Contact lens)។

១៨- ឱសថសារវន្ត — សំដៅដល់ប្រភេទឱសថនៅក្នុងបញ្ជីឱសថសារវន្ត ដែលកំណត់ដោយក្រសួងសុខាភិបាលសម្រាប់មូលដ្ឋានសុខាភិបាលសាធារណៈ។

# ជំពូកទី២
# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
## ផ្នែកទី១
## លក្ខខណ្ឌ

**ប្រការ៤ .-**

ដើម្បីទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សមាជិក **ប.ស.ស**. ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- បានចុះបញ្ជីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីនៅ **ប.ស.ស**.
- បានបង់ភាគទាន ២(ពីរ)ខែជាប់គ្នា។

ករណីសមាជិក **ប.ស.ស**. បានបង់ភាគទាន ២(ពីរ)ខែជាប់គ្នាយ៉ាងតិច សមាជិក **ប.ស.ស**. មានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់រយៈពេល ២(ពីរ)ខែ បន្ទាប់ពីការខកខានបង់ភាគទានតាមកាលបរិច្ឆេទកំណត់។

ករណីសមាជិក **ប.ស.ស**. ជាស្ត្រីមានផ្ទៃពោះ ដែលមានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងបានដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល អាចមានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររហូតដល់កាលបរិច្ឆេទសម្រាលកូន ទោះបីជាមានការខកខានបង់ភាគទានតាមកាលបរិច្ឆេទកំណត់ក៏ដោយ។

**ប្រការ៥ .-**

សមាជិក **ប.ស.ស**. ជាសោធនិកជរាភាពឬទុព្វលភាព និងសមាជិក **ប.ស.ស**. ដែលទទួលបានប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ គិតចាប់ពីកាលបរិច្ឆេទទទួលបានប្រាក់សោធនជរាភាពឬទុព្វលភាព និងប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។

**ប្រការ៦ .-**

សមាជិក **ប.ស.ស**. ដែលបានបំពេញលក្ខខណ្ឌដូចមានកំណត់ក្នុងប្រការ៤ នៃប្រកាសនេះ មានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្របន្តលើករណីចាស់ ដែលមិនមែនជាជំងឺរ៉ាំរ៉ៃនៅមូលដ្ឋានសុខាភិបាលដៃគូ **ប.ស.ស**. រហូតដល់រយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃ ក្នុងអំឡុងពេល១២(ដប់ពីរ)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទចូលប្រើប្រាស់សេវាដំបូង។

## ផ្នែកទី២
## បែបបទ និងនីតិវិធី

**ប្រការ៧ .-**

សមាជិក **ប.ស.ស**. ដែលមានគ្រោះថ្នាក់ ឬជំងឺក្រៅពីហានិភ័យការងារ អាចទៅទទួលសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រនៅតាមមូលដ្ឋានសុខាភិបាលដៃគូ **ប.ស.ស**. ដោយត្រូវភ្ជាប់មកជាមួយនូវ៖

១- ប័ណ្ណសមាជិក **ប.ស.ស**. មានសុពលភាព និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំពោះបុគ្គលនៃវិស័យសាធារណៈ។

២- ប័ណ្ណសមាជិក **ប.ស.ស**. មានសុពលភាព ចំពោះបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

ករណីសង្គ្រោះបន្ទាន់ សមាជិក **ប.ស.ស**. អាចទៅទទួលសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រនៅមូលដ្ឋានសុខាភិបាលដែលជិតបំផុត។ ក្នុងករណីនេះ **ប.ស.ស**. នឹងធ្វើការទូទាត់ថ្លៃសេវាជូនវិញដោយឈរលើយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ដែលកំណត់ដោយ **ប.ស.ស**. ស្របតាមច្បាប់ជាធរមាន។

ពាក្យស្នើសុំតាវកាលិកផ្នែកថែទាំសុខភាពត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស**.។

## ជំពូកទី៣
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាស្តារនីតិសម្បទា
### ផ្នែកទី១
### លក្ខខណ្ឌ

**ប្រការ៨ .-**

សមាជិក **ប.ស.ស**. ដែលទទួលរងគ្រោះថ្នាក់ឬជំងឺក្រៅពីហានិភ័យការងារ មានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រសម្រាប់គាំទ្រដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ឬពិការភាពបន្ទាប់ពីទទួលសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ។

**ប្រការ៩ .-**

ដើម្បីទទួលបានសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ សមាជិក **ប.ស.ស**. ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- មានប័ណ្ណសមាជិក **ប.ស.ស**. មានសុពលភាព
- បានទទួលរងគ្រោះថ្នាក់ ឬជំងឺក្រៅពីហានិភ័យការងារក្នុងកំលុងពេលប័ណ្ណសមាជិក **ប.ស.ស**. មានសុពលភាព
- បង្ហាញខ្លួនចំពោះមុខមន្ត្រីជំនាញរបស់ **ប.ស.ស**. ដើម្បីពិនិត្យ វាយតម្លៃ និងតម្រង់ទិសការផ្តល់សេវា។

### ផ្នែកទី២
### បែបបទ និងនីតិវិធី

**ប្រការ១០ .-**

សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលជាដៃគូ **ប.ស.ស**. សម្រាប់គាំទ្រកំលុងពេលផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ លើកលែងតែមានការស្នើសុំរបស់សាមីជនក្នុងការប្រើប្រាស់សេវាស្តារនីតិសម្បទានៅតាមអង្គភាពផ្តល់សេវាស្តារនីតិសម្បទាផ្សេងទៀតស្របតាមការកំណត់របស់ **ប.ស.ស**.។

**ប្រការ១១ .-**

សមាជិក **ប.ស.ស**. ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរមក **ប.ស.ស**. ដើម្បីប្រើប្រាស់សេវាស្តារនីតិសម្បទា ដោយមានភ្ជាប់មកជាមួយនូវវេជ្ជបញ្ជារបស់មូលដ្ឋានសុខាភិបាលជាដៃគូ **ប.ស.ស**. ឬទម្រង់វាយតម្លៃតម្រូវការសេវាស្តារនីតិសម្បទាពីអង្គភាពផ្តល់សេវាស្តារនីតិសម្បទាផ្សេងទៀត។

ការស្នើសុំនេះត្រូវធ្វើឡើងដោយសាមីជនផ្ទាល់ ឬអ្នកតំណាងក្នុងករណីស្ថានភាពរបួស ឬពិការភាពរបស់សមាជិក **ប.ស.ស**. មានសភាពធ្ងន់ធ្ងរ។

ពាក្យស្នើសុំសេវាស្ដារនីតិសម្បទាត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

## ជំពូកទី៤
## សេវា ឬការព្យាបាលនិងការថែទាំវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូល

**ប្រការ១២ .-**

សេវា ឬការព្យាបាលនិងការថែទាំវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូលក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ចនេះរួមមាន៖

១- ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ។

២- ការថែទាំធ្មេញ (ការសម្អាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)។

៣- ការព្យាបាល និងការវះកាត់ប្ដូរភេទ។

៤- ការផ្សាំ ឬប្ដូរសរីរាង្គផ្សេងៗ។

៥- សេវាបង្កកំណើតដោយសិប្បនិម្មិត។

៦- ការព្យាបាលដោយខ្លួនឯង។

៧- ការព្យាបាល ឬការវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ។

៨- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត ឧបករណ៍ជំនួយភ្នែក និងភ្នែកសិប្បនិម្មិត។

៩- ការព្យាបាលដោយកាំរស្មីឡាស៊ែរ។

១០- ការព្យាបាលញៀនសុរា និងផ្ដាច់គ្រឿងញៀន។

១១- ការព្យាបាលអសមត្ថភាពផ្ដល់កំណើត។

១២- ការវះកាត់បេះដូង និងសសៃឈាមបេះដូង។

១៣- ការលាងឈាម។

១៤- ការពិនិត្យសុខភាពទូទៅ។

ក្នុងករណីសង្គ្រោះបន្ទាន់ សេវា ឬការព្យាបាលនិងការថែទាំវេជ្ជសាស្ត្រដូចមានចែងខាងលើ ត្រូវបានផ្ដល់ជូនសមាជិក **ប.ស.ស.** ស្របតាមលក្ខខណ្ឌដែលមានកំណត់ក្នុងប្រការ៤ នៃប្រកាសនេះ។

## ជំពូកទី៥
## ការផ្ដល់សេវាបង្ការសុខភាព
### ផ្នែកទី១
### ការកំណត់សេវាបង្ការសុខភាព

**ប្រការ១៣ .-**

សេវាបង្ការសុខភាពក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច ត្រូវបានកំណត់ដូចខាងក្រោម៖

១- សេវាចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត (Rabies Vaccination)។

២- សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត (Antirabic Serum)។

៣- សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស (Anti-Tetanus Serum)។

៤- សេវាចាក់សេរ៉ូមប្រឆាំងពិសពស់ ( Antivenom Immunoglubulin )។

៥- សេវាពិនិត្យឈាមរកជំងឺពកក រួមមាន TSH ( Thyroid-stimulating Hormone ), Free T3 ( Free Triiodothyronine ) និង Free T4 ( Free Thyroxine )។

៦- សេវាពិនិត្យឈាមកំណត់អបោជាតុមហារីក ( Cancer Humeraux Marqueurs ) ក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬក្រោយការព្យាបាលជំងឺមហារីកដោយចាក់គីមី និង/ឬក្រោយការព្យាបាលជំងឺមហារីកដោយបាញ់កាំរស្មីអ៊ិច រួមមាន CEA ( Carcinoembryonic Antigen), CA15-3 (Cancer Antigen15-3), CA19-9 (Cancer Antigen19-9), CA125 (Cancer Antigen125), PSA (Prostate-Specific-Antigen), -HCG (Beta-Human Chorionic Gonadotropin)។

## ផ្នែកទី២
## លក្ខខណ្ឌនៃការផ្តល់សេវាបង្ការសុខភាព

**ប្រការ១៤ .-**

ដើម្បីអាចទទួលបានសេវាបង្ការសុខភាព សមាជិក **ប.ស.ស**. ត្រូវបំពេញលក្ខខណ្ឌដូចមានកំណត់ក្នុងប្រការ៤ នៃប្រកាសនេះ។

## ផ្នែកទី៣
## បែបបទនិងនីតិវិធីនៃការផ្តល់សេវាបង្ការសុខភាព

**ប្រការ១៥ .-**

សមាជិក **ប.ស.ស**. អាចទទួលបានសេវាបង្ការសុខភាពដូចមានកំណត់ក្នុងប្រការ១៣ នៃប្រកាសនេះ នៅមូលដ្ឋានសុខាភិបាលជាដៃគូ **ប.ស.ស**.។

សមាជិក **ប.ស.ស**. ត្រូវរ៉ាប់រងចំណាយដោយផ្ទាល់ចំពោះការប្រើប្រាស់សេវាបង្ការសុខភាពនៅតាមមូលដ្ឋានសុខាភិបាលឯកជន ឬមន្ទីរពិសោធន៍ឯកជនទាំងក្នុង និងក្រៅប្រទេស លើកលែងតែមានការអនុញ្ញាតជាមុនពី **ប.ស.ស**.។

## ជំពូកទី៦
## ការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃ

**ប្រការ១៦ .-**

ប្រភេទជំងឺរ៉ាំរ៉ៃក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច ត្រូវកំណត់ដូចខាងក្រោម៖

១- ជំងឺខ្សោយបេះដូង (Cardiac Failure)។

២- ជំងឺសាច់ដុំបេះដូង (Cardiomyopathy)។

៣- ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)។

៤- ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)។

៥- ជំងឺតម្រងនោមរ៉ាំរ៉ៃ (Chronic Kidney Disease)។

៦- ជំងឺក្រិនថ្លើម (Cirrhosis of the Liver)។

៧- ជំងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)។

៨- ជំងឺវិបត្តិចង្វាក់បេះដូង (Cardiac Dysrhythmias)។

៩- ជំងឺក្រិនសរីរាង្គ (Multiple Sclerosis)។

១០- ជំងឺវិកលចរិក (Schizophrenia)។

១១- ជំងឺលុយពុស (Systemic Lupus Erythematosus)។

១២- ជំងឺតាឡាសេមី (Thalassemia)។

**ប្រការ១៧ .-**

សេវាព្យាបាលនិងថៃទាំវេជ្ជសាស្ត្រចំពោះជំងឺពុំរ៉ៃដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈនិងត្រូវប្រើប្រាស់ឱសថសារវន្ត។ ចំពោះឱសថព្យាបាលក្រៅពីបញ្ជីឱសថសារវន្តជាបន្ទុកចំណាយផ្ទាល់របស់អ្នកជំងឺ វៀរលែងតែឱសថសម្រាប់ការព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម មិនមាននៅក្នុងបញ្ជីឱសថសារវន្ត និងការព្យាបាលជំងឺមហារីកដោយសារជាតុគីមី ត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗកំណត់ដោយ **ប.ស.ស.**។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៩ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ